# សេចក្តីប្រកាសព័ត៌មាន

## ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០១៤

### ក្រុមសិក្សាស្រាវជ្រាវជប៉ុន
### សំរាប់ជួយដល់កំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា

ក្រុមសិក្សាស្រាវជ្រាវផ្នែកបច្ចេកទេសរបស់រដ្ឋាភិបាលជប៉ុន ដើម្បីត្រៀមរៀបចំផ្តល់ជំនួយដល់កំណែទម្រង់ការបោះឆ្នោតរបស់កម្ពុជា បានបញ្ចប់ការងាររបស់ខ្លួនតាមកាលកំណត់នៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៤។ នៅក្នុងកំឡុងពេលបេសកកម្មដែលបានចាប់ផ្តើមពីថ្ងៃទី ១៩ ខែឧសភា ក្រុមសិក្សាស្រាវជ្រាវបានធ្វើការពិភាក្សាល្អិតល្អន់និងប្រកបដោយអត្ថន័យជាមួយភាគីពាក់ពន្ធ័សំខាន់ៗនានា ដូចជា សមាជិកគណៈកម្មាការចម្រុះគណបក្សប្រជាជន-គណបក្សសង្គ្រោះជាតិដើម្បីសិក្សានិងរៀបចំក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ អាជ្ញាធរពាក់ព័ន្ធការងារបោះឆ្នោត ដៃគូអភិវឌ្ឍន៏បរទេស អង្គការអន្តរជាតិ និងតំណាងសង្គមស៊ីវិល ។

ផ្អែកលើការរកឃើញនិងលទ្ធផលនៃបេសកកម្មលើកនេះ រដ្ឋាភិបាលជប៉ុននឹងពិចារណាអំពីវិធីសមស្របដើម្បីជួយដល់កំណែទម្រង់ការបោះឆ្នោះរបស់កម្ពុជា ដោយរក្សាទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធដទៃទៀត។

ប្រទេសជប៉ុនចាត់ទុកថា ជំនួយរបស់យើងនឹងមានប្រយោជន៏លុះត្រាតែនៅពេលដែលជំនួយនេះផ្អែកលើការព្រមព្រៀងផ្នែកនយោបាយដ៏ល្អលើបញ្ហានេះ រវាងគណបក្សនយោបាយធំៗនៅប្រទេសកម្ពុជា ។ ក្នុងន័យនេះ យើងសង្ឃឹមយ៉ាងមុតមាំថា ការពិភាក្សាកំពុងបន្តរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិ នឹងបញ្ចប់ដោយជោគជ័យក្នុងពេលដ៏ឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

---

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងជាមួយលោក **ហ្វូមីអូ ហ្គោតូ** (ទូរស័ព្ទដៃលេខ ០១៦-៨៣៥ ៤០៦ អ៊ីមែល : fumio.goto@mofa.go.jp) ។

ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ ១៩៤ មហាវិថីព្រះនរោត្តម ទូរសព្ទ័: ០២៣- ២១៧ ១៦១/៤ ទូរសារ: ០២៣-២១៦ ១៦២

វេបសាយផ្លូវការ : www.kh.emb-japan.go.jp